# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីទោសនៃការផឹកការជក់គ្រឿងស្រវឹងគ្រឿងញៀន

**Website: www.hoksavann.org**

ថ្ងៃទី៧ វិច្ឆិកា ២០០៤

ព្រះពុទ្ធជាម្ចាស់សំដែងអំពីទោស នៃការផឹកការជក់គ្រឿងស្រវឹង គ្រឿងញៀនមានស្រាជាដើមនេះ ពុំមែនព្រះអង្គបង្កើតឲ្យមានទោសទេ គឺទោសកើតមកអំពីការផឹកការជក់នេះឯង ។ ទោសនៃការផឹកស្រា៦យ៉ាងរមែងកើតឡើងក្នុងបច្ចុប្បន្ន ៖

១- សន្និដ្ឋិកា ធនជានិ វិនាសទ្រព្យសម្បត្តិក្នុងបច្ចុប្បន្ននេះ សេចក្ដីថាគ្រួសារមួយចំណាយក្នុងមួយខែសំរាប់ចំណីអាហារ, ប្រដាប់ប្រដាប្រើប្រាស់អស់ប៉ុណ្ណោះ ប៉ុន្តែបើក្នុងចំណោមគ្រួសារនោះ មានសមាជិកគ្រួសារណាម្នាក់ផឹកស្រាផង នោះត្រូវចំណាយប្រាក់កាសថែមទៀត ដែលជាការចំណាយលើសធម្មតានៃថវិកាគ្រួសារដែលធ្លាប់ចំណាយមក ដែលជាការចំណាយចំពោះវត្ថុដែលពុំមែនជាការចាំបាច់សំរាប់ជីវិត ។

២- កលហប្បវឌ្ឍនី នាំបង្កើតជម្លោះ = អ្នកផឹកស្រាតែងមានស្មារតីពុំនឹងនមាត់រអិលនិយាយគ្មានដឹងខុសត្រូវ ដែលជាហេតុនាំបង្កើតជម្លោះជាមួយគ្រួសារខ្លួន រហូតមានជម្លោះជាមួយអ្នកដទៃដែលនាំឲ្យមានសត្រូវដល់ខ្លួន ។

៣- រោគានំ អាយតនំ ជាហេតុនាំឲ្យកើតរោគ = ស្រាជាភេសជ្ជៈមានជាតិពុលមានធាតុក្តៅ ផឹកច្រើននាំឲ្យអាការៈក្នុងខ្លួនដើរខុសប្រក្រតី ដែលបណ្ដាលឲ្យកើតជាជម្ងឺផ្សេងៗ ។ តាមវេជ្ជបណ្ឌិតបានពិនិត្យឃើញថា ជម្ងឺខ្លះដូចជាជម្ងឺក្រពះជម្ងឺថ្លើមជម្ងឺសួត មួយភាគបណ្ដាលមកពីការផឹកស្រាច្រើន ។

៤- អកិត្តិសញ្ជននី មានកេរ្តិ៍ឈ្មោះអាក្រក់ = អ្នកផឹកស្រាតែងមានកេរ្តិ៍ឈ្មោះអាក្រក់, អ្នកដទៃពុំរាប់រក គេពុំជឿទុកចិត្ត ហើយមានឥទ្ធិពលអាក្រក់មកដល់កូនទៀត បើទោះបីកូនពុំផឹកស្រាដូចឪពុកឬម្ដាយក៏ដោយ ក៏ញញើតក្នុងការស្ដីដណ្ដឹងកូន ព្រោះគេគិតដល់ពូជអម្បូរណ៍អ្នកផឹកស្រានេះឯង ដូចពាក្យខ្មែរថា ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន ។

៥- កោបិននិទំសនី បង្ហាញកេរ្តិ៍ខ្មាស់ = អ្នកផឹកស្រាច្រើនរហូតក្លាយជាប្រមឹកគ្មានអៀនខ្មាស់អ្វីឡើយ ទាំងសំលៀកបំពាក់ទាំងសំដីនិយាយ ទាំងឥរិយាបថទាំង៤ ដេកដើរឈរអង្គុយ ពុំបានសមរម្យឡើយ ។

៦- បញ្ញាយ ទុព្វលីករណី ធ្វើឲ្យខ្សោយប្រាជ្ញាស្មារតី = អ្នកផឹកស្រាច្រើនតែងធ្វើឲ្យក្ដៅសរសៃប្រសាទ មានសរសៃខួរក្បាលជាដើម ទៅជាវង្វេងភ្លេចភ្លាំងស្មារតីបញ្ញាចុះខ្សោយ ។ ដោយភាពទន់ខ្សោយប្រាជ្ញាស្មារតី មានអ្នកផឹកស្រាខ្លះបានប្រើអំពើហឹង្សារករឿងវាយដំប្រពន្ធកូនថែមទៀតផង ។ មិនតែប៉ុណ្ណោះ មានអ្នកស្រវឹងស្រាខ្លះប្រព្រឹត្តចោរកម្ម ដើម្បីបានប្រាក់យកមកទិញស្រាផឹកទៀត ។

ក្នុងសិក្ខាបទទាំង៥នៃសីល៥ ដែលព្រះពុទ្ធហាមមិនឲ្យផឹកស្រាថាជាទីតាំងនៃសេចក្ដីប្រមាទនោះ ព្រោះអ្នកផឹកស្រាជោគជាំរាល់ថ្ងៃនាំឲ្យភ្លេចបំពេញសេចក្ដីល្អខាងកុសល ហើយធ្វេសប្រហែសក្នុងកិច្ចការគ្រប់យ៉ាងដែលខ្លួនត្រូវបំពេញ ព្រោះអ្នកផឹកស្រាច្រើនចាត់ទុកថាជាអ្នកមានជម្ងឺស្រវឹង ពុំអាចធ្វើការងារតាមផ្លូវកាយផ្លូវប្រាជ្ញា ឲ្យបានមាំទាំនិងទាន់ពេលវេលាឡើយ ។ ជួនកាលការងារដែលចាំបាច់ត្រូវពេលនេះថាចាំសំរាកឬដេកបន្តិចទៀតសិន ឬក៏ថាចាំស្វាងស្រាសិន នេះឯងដែលហៅថាជាទីតាំងនៃសេចក្ដីប្រមាទ ។ នៅក្នុងមង្គលសូត្រពោលថា ការសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹងជាមង្គលដ៏ឧត្តម ។

មិនចំពោះតែស្រាទេ ភេសជ្ជៈដទៃទៀតឲ្យតែផឹកទៅស្រវឹង ត្រូវចាត់ចូលក្នុងប្រភេទស្រា ដែលនាំឲ្យមានទោសដូចគ្នា ។ មានភេសជ្ជៈទំនើបខ្លះខ្លាំងជាងស្រាក៏មាន ។ ភេសជ្ជៈទំនើបទាំងនេះ មិនមាននិយាយនៅក្នុងសិក្ខាបទស្រានេះ ព្រោះសម័យពុទ្ធកាលពុំទាន់មាន ។ មានភេសជ្ជៈខ្លះដែលគេធ្លាប់ស្គាល់ដូចជា Beer, wisky ជាដើម ឬទឹកត្នោតជូរជាភេសជ្ជៈរបស់ខ្មែរនៅខ្សោយជាងស្រា ។

គ្រឿងជក់គ្រឿងហិតដូចជាអាភៀនកញ្ឆា កាកូអ៊ីនជាដើម បើជក់ឬហិតទៅ នាំឲ្យពុលខូចសុខភាព ចាត់ចូលក្នុងលក្ខណៈស្រាទាំងអស់ ។ ពិសេសចំពោះអាភៀនដាំក្ដី លក់ដូរក្ដី ជក់ក្ដី មានទោសធ្ងន់ជាទោសឧក្រិដ្ឋប្រទេសខ្លះកាត់ទោសប្រហារជីវិតផង ។ អាភៀនមានគ្រោះថ្នាក់ខ្លាំងណាស់ទៅលើសុខភាពរបស់មនុស្សដែលប្រើវា បានជាគេត្រូវបំបាត់ជាអន្តរជាតិ ។ បារីក៏ជាថ្នាំមួយធ្វើឲ្យអ្នកជក់កើតរោគដែរ ។ តាមវេជ្ជបណ្ឌិតពិនិត្យទៅឃើញថា មានរោគកើតនៅក្នុងសួតមួយប្រភេទ កើតមកអំពីការជក់បារី ។ សព្វថ្ងៃនេះ នៅកន្លែងសាធារណៈ ដូចជាមន្ទីរពេទ្យ សាលារៀន ការិយាល័យ កន្លែងធ្វើការគ្រប់កន្លែង តាមយន្តហោះ គេហាមមិនឲ្យជក់បារីឡើយ ។ នៅសហរដ្ឋអាមេរិក មានខ្មែរម្នាក់យកកូនទៅមន្ទីរពេទ្យមើលជម្ងឺ ។ គ្រូពេទ្យពិនិត្យទៅឃើញថា កូននោះឈឺព្រោះមានផ្សែងបារីចូលទៅក្នុងសួត ។ ឪពុកបានប្រាប់គ្រូពេទ្យថា គ្រួសារខ្លួនឥតមានជក់ទេ ចុះផ្សែងបារីនោះមកពីណា គិតមួយសន្ទុះទើបនឹកឃើញកាលមុននេះមួយថ្ងៃ ខ្លួនបានយកកូនទៅវត្ត ទើបសន្និដ្ឋានកូនខ្លួនចូលផ្សែងបារីដែលព្រះសង្ឃឆាន់ក្នុងវត្ត ។ ដូច្នេះ ព្រះសង្ឃខ្មែរណាដែលឆាន់បារីគួរឈប់ឆាន់ ហើយពុទ្ធបរិស័ទគួរឈប់ប្រគេនបារីលោកទៀត ព្រោះឆាន់ទៅនាំឲ្យខូចសុខភាពផង ហើយប៉ះពាល់ដល់សាធារណជនដែលមកធ្វើបុណ្យផងជាទានមិនបានបុណ្យទេ ព្រោះជាទាននាំខូចសុខភាព ។

បញ្ហាផឹកស្រា ខ្លះថាគេផឹកស្រាដើម្បីបំបាត់ទុក្ខឬបំភ្លេចទុក្ខ ។ តាមពិតសេចក្ដីទុក្ខមកអំពីមានបញ្ហាដែលនាំឲ្យកើតទុក្ខ គឺសេចក្ដីទុក្ខត្រូវរលត់បើបានដោះស្រាយបញ្ហាដែលនាំឲ្យកើតទុក្ខ ។ ស្រាពុំអាចជួយបំបាត់ទុក្ខបានទេ ផ្ទុយទៅវិញ ទុក្ខកើតមានមួយជាន់ថែមទៀត ដោយទោសនៃការផឹកស្រានេះឯង ។ ការផឹកស្រាថ្នាំ ដូចជាស្ត្រីខ្មែរនៅឆ្ងាយពីមន្ទីរពេទ្យជាអ្នកក្រីក្រភាគច្រើន ឆ្លងទន្លេនៅផ្ទះ រួចអាំងភ្លើងនិងផឹកស្រាថ្នាំ ស្ត្រីខ្លះមានជម្ងឺនៅពេលអាំងភ្លើងនោះ ហើយយល់ថាព្រោយក្រឡាភ្លើងធ្វើឲ្យឈឺ ។ តាមពិត ជម្ងឺនោះបណ្ដាលមកពីការដកដង្ហើមស្រូបយកផ្សែងអុសឬផ្សែងធ្យូងដែលដុតអាំងនោះ ដែលមានជាតិពុល និងបណ្ដាលមកពីការផឹកស្រាថ្នាំច្រើន ទៅជាស្រវឹងវិញទេ ។

អំពីទោសនៃការផឹកស្រា ពេលស្លាប់ទៅ នៅក្នុងនិរយកថាដែលនិយាយពីឋាននរក មាននរកមួយឈ្មោះវេត្តរណីនរក ប្រែថានរកផ្ដៅ ឬស្ទឹងទឹកប្រៃ ។ គឺនរកនេះមានស្ទឹងមួយធំមានទឹកប្រៃខ្លាំង ហើយមានផ្ដៅធំៗ មានបន្លាស្រួចមុតដូចកាំបិតកោរ សត្វនរកឃើញទឹកក៏នាំគ្នាទៅផឹក ទឹកក៏ក្លាយទៅជាភ្លើងឆេះពោះក្ដៅងំ ហើយរត់ទៅប៉ះនឹងផ្ដៅដាច់ខ្លួនមុតសាច់ចេញឈាមលំបាកវេទនាយ៉ាងខ្លាំងក្លា ។ ទោសធ្លាក់នរកនេះមកពីជាតិមុនបោកគេស៊ីបាយ ផឹកសុរានិងមេរ័យ កុហកភូតភរគេ មាន

អាហារមានទឹកកំណាញ់មិនធ្វើទាន ។

ដោយស្រាមានគុណវិបត្តិដូចពោលមកហើយ គួររាជរដ្ឋាភិបាលខ្មែរឈប់កុំឲ្យផលិត កុំឲ្យលក់ កុំឲ្យនាំស្រាគ្រប់ប្រភេទចូលប្រទេសកម្ពុជាតទៅទៀត ដូចជាគេបំបាត់អាភៀនដូច្នោះដែរ ។ មួយទៀតមិនត្រូវអនុញ្ញាតឲ្យផ្សាយពាណិជ្ជកម្មស្រានិងបារី នៅលើកញ្ចក់ទូរទស្សន៍តទៅទៀត ។ បើបំបាត់បាននូវអំពើអបាយមុខទាំងបី គឺល្បែងស្រីល្បែងស្រានិងល្បែងស៊ីសងគ្រប់ប្រភេទ ឈ្មោះថាគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទើបសមជាប្រទេសកាន់ព្រះពុទ្ធសាសនា ។៚